ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
លេខ:០១៣.ផស.៧. សក.អល

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ ចេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការបោះពុម្ពឯកសារពាក់ព័ន្ធសេវាកម្មយានយន្ត របស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក និងឯកសារពាក់ព័ន្ធសេវាកម្មដឹកជញ្ជូន របស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ប្រចាំឆ្នាំ ២០១៨

ក្រសួងសាធារណការ និងដឹកជញ្ជូន សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យបានជ្រាបថា ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកបោះពុម្ពឯកសារពាក់ព័ន្ធសេវាកម្មយានយន្ត របស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក និងឯកសារពាក់ព័ន្ធសេវាកម្មដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ប្រចាំឆ្នាំ ២០១៨ ។

ក្រសួងសាធារណការ និងដឹកជញ្ជូន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅ **អង្គភាពលទ្ធកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន** ដែលមានអាសយដ្ឋាននៅអគារមហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (លេខទូរស័ព្ទទំនាក់ទំនង: ០២៣ ៧២២ ០១៣ / ០១២ ២៧៩ ៦៤១ / ០៩៥ ៩៥៥ ០០០) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨ វេលាម៉ោង ៩:៣០ នាទីព្រឹក។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងសាធារណការ និងដឹកជញ្ជូន តាមអាសយដ្ឋានខាងលើ វេលាម៉ោង ៩:៣០ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ជ.រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**
**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**សួង ហេង**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ (កសហវ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
3

ឯកសារដេញថ្លៃ